# សហគមន៍ខ្មែរកម្ពុជាក្រោម-ទ្វីបអាមេរិកខាងជើង

**KHMER KAMPUCHEA KROM COMMUNITY-NORTH AMERICA**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM- L'AMÉRIQUE DU NORD**

## លិខិតចូលរួមមរណទុក្ខ

## ជូន

## លោក សឹន ឃុន ធឿង  លោក សឹន រ៉េត  លោក សឹន សាង

## និងក្រុមគ្រួសាររបស់លោកទាំងអស់

សហគមន៏ខ្មែរកម្ពុជាក្រោម-ទ្វីបអាមេរិកខាងជើង សហសេវិក សមាជិក សមាជិកា និងក្នុងនាមខ្ញុំបាទផ្ទាល់ មានសេចក្តីតក់ស្លុត និងសោកស្តាយជាពន់ពេក ដោយបានទទួលពតិមានដ៏សង្វេគយ៉ាងខ្លាំង ក្នុងការទទួលអនិច្ចកម្មរបស់លោកយាយ **ថាច់ ធី ច័ន្ទ** នាថ្ងៃសៅរ៍ ០១កើត ខែកត្តិក ឆ្នាំកុរ នព្វស័ក ព.ស.២៥៥១ ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា គ.ស.២០០៧ វេលាម៉ោង ០៨:២២នាទីយប់ ដោយជរាពាធ នៅរដ្ឋវ៉ាស៊ីងថិន សហរដ្ឋអាមេរិក។ លោកយាយ **ថាច់ ធី ច័ន្ទ** មានជន្មាយុ ៨៩ឆ្នាំ បានកើតនៅឆ្នាំ១៩១៨ ភូមិបឹងរ៉ែក្រសាំង ឃុំហាន់យ៉ាង និគមថ្កូវ ខេត្តព្រះត្រពាំង កម្ពុជាក្រោម មានកូន ៨នាក់ ប្រុស ៧ និងស្រី ១ លោក សឹន ខេត លោក សឹន ខាន់ លោក សឹន ឃុន ធឿង អ្នកស្រី ថាច់ ធី សំបូ លោក សឹន រ៉េត លោក សឹន ចម្រើន លោក សឹន ស្ម័គ្រ និងលោក សឹន សាង ជាកូនពៅ។ លោកយាយបានបីបាច់ចិញ្ចឹមកូនទាំងអស់តែម្នាក់ឯងគត់ ក្នុងស្ថានភាពជាស្ត្រីមេម៉ាយ និងការលំបាកជាច្រើនឆ្នាំកន្លងមក។ កូនប្រុសទាំងអស់របស់លោកយាយបានកសាងផ្នួស ដើម្បីបុព្វហេតុជាតិមាតុភូមិ និងព្រះពុទ្ធសាសនា តាមការទូន្មានរបស់លោក ។

យើងខ្ញុំបាទ សហសេវិក សមាជិក និងសមាជិកាសហគមន៏ខ្មែរកម្ពុជាក្រោម តាមបណ្តារដ្ឋ ខេត្តនិងក្រុង នៅសហរដ្ឋអាមេរិក និងប្រទេសកាណាដា សូមចូលរួមមរណទុក្ខជាមួយលោកទាំងអស់ និងក្រុមគ្រួសាររបស់លោក ក្នុងគ្រាដ៏មហាលំបាកនេះ ។

យើងខ្ញុំបាទ សហសេវិក សមាជិក និងសមាជិកាសហគមន៏ខ្មែរកម្ពុជាក្រោម-ទ្វីបអាមេរិកខាងជើង សូមគោរពវិញ្ញាណក្ខ័ន្ធលោកយាយ **ថាច់ ធី ច័ន្ទ** នូវវិរភាព និងបូជនីយកិច្ចទាំងឡាយ ដើម្បីជាតិ សាសនា និងគ្រួសារជាទីស្នេហារបស់លោកយាយ ។

សូមវិញ្ញាណក្ខ័ន្ធលោកយាយ អញ្ជើញទៅសោយសុខក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

ទីក្រុងឡូវែល  សហរដ្ឋអាមេរិក      ថ្ងៃទី ១១ ខែ វិច្ឆិកា គ.ស.២០០៧

**គិម ប.ម. សគល**

នាយកប្រតិបត្តិ

Website: www.khmerkromngo.org
Mailing address in the United States & Canada: P.O. Box 1836, Lowell, MA 01853 U.S.A.
E-mail: KKCpressoffice@yahoo.com